# នៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Mar-2021, 10:30
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ភាគីដាក់ឯកសារ៖ | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| ដាក់ជូន៖ | អង្គជំនុំជម្រះតុលាការកំពូល |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ |

## <u>ចំណាត់ថ្នាក់ឯកសារ</u>

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះការកត់សម្គាល់របស់ ខៀវ សំផន ចំពោះកាលវិភាគសវនាការបណ្តឹងសាទុក្ខ ដែលបានស្នើឡើង

---

<u>ដាក់ដោយ</u>៖

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Megan HIRST

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី

Olivier BAHOUGNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY

<u>នៅចំពោះមុខ</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ីម ប្រធាន

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE- MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ម៉ុច សុវណ្ណារី
ស៊ិន ស៊ុវ៉ន
សំ សុគង់
វ៉េន ពៅ
ទី ស្រីនណា

Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

ចៅក្រម យ៉ា ណារិន

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង

Brenda J. HOLLIS

**ជនជាប់ចោទ៖**

ខៀវ សំផន

**សហមេធាវីការពារក្តី៖**

គង់ សំអុន

Anta GUISSÉ

*ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះការកត់សម្គាល់*
*របស់ ខៀវ សំផន ចំពោះកាលវិភាគសវនាការបណ្តឹងសាទុក្ខ ដែលបានស្នើឡើង*

## I. សេចក្ដីផ្ដើម

1. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") បានដាក់សំណើនេះ អនុលោមទៅតាមសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ នៅចំពោះមុខ អ.វ.ត.ក (សេចក្ដីណែនាំអនុវត្ត")[1] ជាការឆ្លើយតបចំពោះការកត់សម្គាល់របស់ ខៀវ សំផន ចំពោះកាលវិភាគសម្រាប់សវនាការលើបណ្ដឹងសាទុក្ខ (សំណុំរឿង ០០២/២) ("ការកត់សម្គាល់របស់មេធាវីការពារក្ដី")[2]។

2. សំណើនេះត្រូវបានដាក់ជូនយ៉ាងលឿនបំផុត ដើម្បីកុំឱ្យមានការយឺតយ៉ាវក្នុងការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") ទៅលើកាលវិភាគនៃការធ្វើសវនាការ។ សហមេធាវីនាំមុខ សូមកត់សំគាល់ថា ក្នុងរយៈពេលនេះ ការបកប្រែជាភាសាអង់គ្លេសនៃការកត់សម្គាល់របស់មេធាវីការពារក្ដីគឺមិនទាន់រួចរាល់នៅឡើយ។

## II. ភាពអាចទទួលយកបាន

3. អង្គជំនុំជម្រះ បានបញ្ជាក់ច្បាស់កន្លងមកហើយថា ការឆ្លើយតបនៅក្នុងកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខទាំងអស់នេះ ត្រូវធ្វើឡើងដោយផ្ទាល់មាត់ប៉ុណ្ណោះ[3]។ ការអញ្ជើញរបស់អង្គជំនុំជម្រះឱ្យដាក់សេចក្ដីសង្កេតនោះ គឺកម្រិតត្រឹមតែកាលវិភាគដែលបានស្នើឡើងដោយអង្គជំនុំជម្រះប៉ុណ្ណោះ[4]។ សំណើសុំរបស់មេធាវីការពារក្ដី គឺលើសពីការអញ្ជើញនោះ ដោយបានលើកឡើងនូវទឡ្ហីករណ៍អង្គសេចក្ដី ពាក់ព័ន្ធសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការឆ្លើយតប។ ផ្នែកមួយដ៏សំខាន់នៃការកត់សម្គាល់របស់មេធាវីការពារក្ដី បង្កើតបានជាការឆ្លើយតប ចំពោះបញ្ហាដែលបានលើកឡើង នៅក្នុងសារណាចម្លើយតប របស់សហមេធាវីនាំមុខ ពាក់ព័ន្ធសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋ

[1] សេចក្ដីណែនាំអនុវត្ត ស្ដីពីការដាក់ឯកសារ នៅចំពោះមុខ អ.វ.ត.ក មាត្រា ៨.៣។

[2] ឯកសារ F60/1 សេចក្ដីសង្កេតរបស់ក្រុមមេធាវីការពារក្ដីលើកាលវិភាគសម្រាប់សវនាការលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ("ការកត់សម្គាល់របស់មេធាវីការពារក្ដី")។

[3] ឯកសារ F49 សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ កថាខណ្ឌ ២២។

[4] ឯកសារ F60 ការអញ្ជើញឱ្យដាក់ សេចក្ដីសង្កេតលើកាលវិភាគ សម្រាប់សវនាការ បណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ទំព័រ ៣។

ប្បវេណី[5]។ ផ្នែកទាំងអស់នេះនៃការកត់សម្គាល់ របស់មេធាវីការពារក្តី គួរត្រូវបានសម្រេចថាមិនអាចទទួលយកបាន ហើយអង្គជំនុំជម្រះមិនត្រូវយកមកពិចារណាឡើយ។ ប្រសិនបើមេធាវីការពារក្តីស្នើសុំធ្វើការឆ្លើយតបចំពោះសំណើសុំនេះ ពេលវេលាដ៏សមស្របនោះគឺនៅក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខ។

## III. សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី

4. ទោះជាក្នុងករណីណាក្តី ការកត់សម្គាល់របស់មេធាវីការពារក្តី គឺមិនត្រឹមត្រូវឡើយ ទាក់ទងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីការពារក្តីហាក់ដូចជាលើកទឡ្ហីករណ៍ថា សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការដាក់សារណាគឺកម្រិតត្រឹមតែការលើកជាមតិយោបល់អំពីភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ[6]។ គោលជំហរយ៉ាងចង្អៀតខ្លាំងនេះ គឺជាការលើកឡើងដែលមិនធ្លាប់មានពីមុន ហើយមិនមានការគាំទ្រនៅក្នុងអត្ថបទច្បាប់របស់ អ.វ.ត.ក នៅក្នុងយុត្តិសាស្ត្រ ឬនៅក្នុងការអនុវត្តរបស់ អ.វ.ត.ក ឡើយ។ មេធាវីការពារក្តីមិនបានយោងទៅរក លិខិតគតិយុត្តិណាមួយឡើយ ដែលគាំទ្រនូវសេចក្តីអះអាងរបស់ខ្លួន ដែលថាដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការស្នើសុំតែរឿងដែលទាក់ទងទៅនឹងភស្តុតាងតែប៉ុណ្ណោះ[7]។ មេធាវីការពារក្តីក៏មិនអើពើឡើយដែល

---

[5] ឯកសារ **F60/1** ការកត់សម្គាល់របស់ មេធាវីការពារក្តី កថាខណ្ឌ ១៣-៣១។

[6] សូមមើលជាឧទាហរណ៍ ឯកសារ **F60/1** ការកត់សម្គាល់របស់ មេធាវីការពារក្តី, កថាខណ្ឌ ២៥, ៣៧ និង ៤៤។

[7] មេធាវីការពារក្តីពឹងផ្អែកជាចម្បងទៅលើ សេចក្តីសម្រេចដោយមតិភាគច្រើនលើសលប់របស់អង្គជំនុំជម្រះសាលាដំបូង ដែលសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណី មិនអាចដាក់សារណាពាក់ព័ន្ធ ការផ្តន្ទាទោស ឬបញ្ហាបច្ចុប្បន្នទាក់ទងអត្តចរិក។ ទោះជាយ៉ាងនេះក្តី សូម្បីតែសេចក្តីសម្រេចនោះ ក៏មិនបានឈានដល់ថ្នាក់កម្រិតសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រឹមតែភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីដែរ។ ចំពោះគោលការណ៍ជាមូលដ្ឋាន សហមេធាវីនាំមុខបានដាក់សារណារួចហើយ ពាក់ព័ន្ធមូលហេតុដែលមតិភាគច្រើនលើសលប់ នៅក្នុងសេចក្តីសម្រេចឆ្នាំ២០១៩ របស់អង្គជំនុំជម្រះសាលាដំបូង ខុសៈ សូមមើល ឯកសារ **F54/2** ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២ ថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ កថាខណ្ឌ ៨៤៨-៨៦៣ 848-863 ("ចម្លើយតបរបស់ សហមេធាវីនាំមុខ") និងសំណុំរឿង ០០១ ឯកសារ **E72/3** សេចក្តីសម្រេចលើសំណើរួម របស់សហមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេច អំពីសិទ្ធិរបស់សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋាន ទាក់ទងការផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរ ជនជាប់ចោទ អ្នកជំនាញ និងសាក្សី ដែលបានកោះហៅឱ្យផ្តល់សក្ខីកម្ម ទាក់ទងនឹងអត្តចរិត របស់ជនជាប់ចោទ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩។

ថា នៅក្នុងអំឡុងដំណើរការនីតិវិធីជម្រះក្តីនៃសំណុំរឿង ០០២/០២[8] ដើមបណ្តឹងរដ្ឋប្បវេណីបាន លើកឡើងនូវសារណាជាច្រើន លើប្រធានបទច្រើនចម្រុះគ្នា ដែលនាពេលនេះមេធាវីការពារក្តី បាន អះអាងថាស្ថិតក្រៅសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅវិញ រួមទាំងបញ្ហាពាក់ព័ន្ធភាពយុត្តិធម៌នៃ កិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តី លើបញ្ហាផ្សេងក្រៅពីភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី[9] លើ វិសាលភាពនៃសំណុំរឿង និងបទចោទដែលនៅសេសសល់[10] ព្រមទាំងធាតុផ្សំឧក្រិដ្ឋកម្មដែលអាច

---

[8] ឧទាហរណ៍ទាំងឡាយដែលបានផ្តល់ក្នុងជើងទំព័រខាងក្រោម គឺយកមកពីសារណាជាលាយលក្ខណ៍អក្សរ និង សេចក្តីសន្និដ្ឋាន បញ្ចប់កិច្ចពិភាក្សាដេញដោល ដែលទាក់ទងទៅនឹងដំណាក់កាលជម្រះក្តីនៃសំណុំរឿង ០០២/០២ ។ ក៏ប៉ុន្តែឧទាហរណ៍ជាច្រើន ផ្សេងទៀត អាចរកឃើញពីសំណុំរឿង ០០២/០១ និង សំណុំរឿង ០០១ ក៏ដូចជា សេចក្តីសន្និដ្ឋានផ្ទាល់មាត់ និង ឯកសារដែល បានដាក់មុនការជម្រះក្តី។

[9] សូមមើលជាឧទាហរណ៍៖ ឯកសារ **E321/1** ការគាំទ្ររបស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅលើសំណើ របស់ សហព្រះរាជអាជ្ញា សុំចាត់តាំងក្រុមមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤, ឯកសារ **E350/3** សេចក្តីសន្និដ្ឋានរបស់ សហមេធាវីនាំមុខ ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹង ភាពអាចទទួលយកបាន និងការអនុញ្ញាតដោយច្បាប់ ឲ្យប្រើប្រាស់ភស្តុតាងដែលបាន មកពីការធ្វើទារុណកម្ម ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥, ឯកសារ **E355/2** សារណាតបរបស់ សហមេធាវីនាំមុខតំណាង ដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសំណើរួមរបស់ ក្រុម មេធាវីការពារក្តី ស្តីពីការអនុវត្តមួយចំនួន ពាក់ព័ន្ធនឹងសាក្សីនិងអ្នកជំនាញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥, ឯកសារ **E392/1** ចម្លើយតបរបស់សហមេធាវីនាំមុខ ទៅនឹងសំណើទីពីរ និងទីបីរបស់ នួន ជា ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ២០-២១, ឯកសារ **E395/5** ចម្លើយតបរបស់សហមេធាវីនាំមុខ ទៅនឹងសារណារបស់ នួន ជា ស្តីពីភាពពាក់ព័ន្ធនឹងភស្តុតាង អំពីការបះបោរក្បត់ ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦, ឯកសារ **F53/5** ចម្លើយតបរបស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសំណើ របស់ ខៀវ សំផន សុំប្តឹងជំទាស់ចិត្តចៅក្រម៦រូប នៃអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩

[10] សូមមើលជាឧទាហរណ៍៖ ឯកសារ **E301/5/3** សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្តីអំពីវិសាលភាពនៃសំណុំរឿង ០០២/ ០២ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤, ឯកសារ **E306/7** សារណារបស់សហមេធាវីនាំមុខ ដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាម វិធាន ៩២ នៃវិធានផ្ទៃក្នុង ស្តីពីការបញ្ជាក់អំពី វិសាលភាពនៃសំណុំរឿង ០០២/២ ទាក់ទងនឹងបទចោទ នៃការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦, ឯកសារ **E306/7/2** ការឆ្លើយតបរបស់សហ មេធាវីនាំមុខ ទៅនឹងចម្លើយរបស់ មេធាវីការពារក្តី ខៀវ សំផន តបសំណើសុំការបញ្ជាក់បំភ្លឺ ស្តីពីការរំលោភសេពសន្ថវៈ នៅក្រៅ អាពាហ៍ពិពាហ៍ដោយបង្ខំ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦, ឯកសារ **E392/1** ចម្លើយតបរបស់សហមេធាវីនាំមុខ ទៅនឹងសំណើទីពីរ និងទីបីរបស់ នួន ជា ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ១៤-១៧, ឯកសារ **E439** សំណើរបស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំសេចក្តីបញ្ជាក់ទាក់ទងនឹង បទចោទដែលនៅសេស សល់ ក្នុងសំណុំរឿង ០០២ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៦, ឯកសារ **E306/7/3/1/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ចំពោះសំណើសុំការបញ្ជាក់ពី វិសាល

អនុវត្តបាន[11]។ ទាំងអស់នេះ គឺជាបញ្ហាដែល ដើមបណ្តឹងរដ្ឋប្បវេណី មានផលប្រយោជន៍ដោយផ្ទាល់។ ដូចដែលអង្គជំនុំជម្រះបានទទួលស្គាល់ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការឆ្លើយតបនៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ បានឆ្លុះបញ្ចាំងអំពីសិទ្ធិរបស់ពួកគេ នៅក្នុងកិច្ចដំណើរការនីតិវិធីស៊ើបអង្កេត និងជំនុំជម្រះ៖

> ជាមួយនឹងសហមេធាវីនាំមុខត្រង់ចំណុចថា [...] *ទឡ្ហីករណ៍នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី សិទ្ធិខ្លួនក្នុងការជំទាស់ទៅនឹងបណ្តឹងសាទុក្ខនេះ កើតចេញយ៉ាងសមហេតុផលពីបុព្វសិទ្ធិ ដែលបានផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលស៊ើបអង្កេត ដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបណ្តឹងសាទុក្ខ*។ ជាពិសេសអង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា "*ភាគី*" មានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ នៅចំពោះមុខអង្គជំនុំជម្រះដែលមានសមត្ថកិច្ច រហូតដល់ពេលដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដូចមានចែងយ៉ាងលម្អិតនៅក្នុង សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ការអនុញ្ញាតឲ្យដាក់បណ្តឹង និងសារណាជាលាយលក្ខណ៍អក្សរ រួមបញ្ចូលយ៉ាងសមហេតុផល នូវសិទ្ធិដាក់សារណាតប និងការឆ្លើយតបទៅនឹង សេចក្តីសន្និដ្ឋានរបស់ភាគីមួយទៀត ដែលស្របទៅតាមក្របខណ្ឌនៃកិច្ចដំណើរការនីតិវិធីចំពោះមុខ។ ដូច្នេះ *ការមិនទទួលស្គាល់*សិទ្ធិរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី នៅក្នុងដំណាក់កាលនេះ គឺជាការមិនស្របទៅនឹង *សិទ្ធិរបស់ដើម*

ភាពទាក់ទងនឹងបទចោទ នៃការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦។ សហមេធាវីនាំមុខកត់សម្គាល់ថា ពួកគេបានដាក់សារណា នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង ០០២/០២ ជាចម្លើយតបចំពោះ សេចក្តីសន្និដ្ឋានលើវិសាលភាព របស់មេធាវីការពារក្តី។ សូមមើល ឯកសារ E1/526.1 ប្រតិចារឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល) ទំព័រ ៥៤ និងទំព័របន្តបន្ទាប់នៅក្រោយ [13.32.30]។ បញ្ជីនេះនៅមានច្រើនបន្តទៀត ហើយមិនបានយោងទៅរក ករណីមួយចំនួនដែល ប្រធានបទទាំងអស់នេះ ត្រូវបានលើកឡើងនៅក្នុងការជំនុំជម្រះ ហើយដែលសហមេធាវីនាំមុខ បានលើកឡើងជាសារណាផ្ទាល់មាត់។

[11] ឯកសារ **E457/6/2** សារណាបញ្ចប់ការពិភាក្សាដេញដោល របស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ៩៩ -១០៤។ សូមមើលផងដែរ ឯកសារ **E1/520.1** ប្រតិចារឹក (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល) ទំព័រ ៨៦ និងទំព័របន្តបន្ទាប់ នៅក្រោយ [13.58.19]។

*បណ្ដឹងរដ្ឋប្បវេណី ទាក់ទងនឹងតួនាទីជាទូទៅរបស់ពួកគេ នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី*[12]។

5. អង្គជំនុំជម្រះមិនបានកម្រិតវិសាលភាពនៃសារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ តែត្រឹមប្រធានបទនៃភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះឡើយ។ ការណ៍ដែលសហមេធាវីនាំមុខ ផ្ដោតទៅលើបញ្ហាជាក់លាក់ នៅក្នុងបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ មិនបានបង្ហាញថា សិទ្ធិរបស់ពួកគេត្រូវបានកម្រិតកំណត់ តែទៅលើបញ្ហាទាំងអស់នោះឡើយ[13]។ មេធាវីការពារក្ដីហាក់ដូចជាជឿជាក់ថា គូភាគីត្រូវបានសន្មតថា ត្រូវលើកទឡ្ហីករណ៍លើ*គ្រប់*បញ្ហាទាំងអស់ ដែលស្ថិតក្នុងសិទ្ធិរបស់ខ្លួន។ ប៉ុន្តែភាគីភាគច្រើន សម្រេចលើកយកបញ្ហាមួយចំនួនតិចតួចមកជំទាស់តែប៉ុណ្ណោះ ដោយផ្អែកលើកត្តាជាច្រើនផ្សេងគ្នា ដែលក្នុងនោះរួមមានយុទ្ធសាស្ត្រសំណុំរឿង និងការបែងចែកធនធានដែលមានកម្រិត។ លទ្ធផលនៃសេចក្ដីសម្រេចបែបនេះ ទោះជាក្នុងករណីណាក្ដី មិនអាចត្រូវបានប្រើប្រាស់ ដើម្បីបង្ហាញអំពីគោលជំហរ ទាក់ទងនឹងសិទ្ធិនោះឡើយ។

6. មេធាវីការពារក្ដីមិនបានផ្ដល់ការពន្យល់ សម្រាប់ការអះអាងរបស់ខ្លួនដែលថា ប្រធានបទមួយចំនួន (ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី បណ្ដឹង នីត្យានុកូលភាព ធាតុផ្សំឧក្រិដ្ឋកម្ម) មិនប៉ះពាល់ដោយផ្ទាល់ទៅលើផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្វីដែលខ្លួនយល់ថាជា "ផលប្រយោជន៍ដើមបណ្ដឹងរដ្ឋប្បវេណី"។ សារណាលម្អិតមាននៅក្នុងចម្លើយតបរបស់សហមេធាវីនាំមុខ ដែលពន្យល់អំពីសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងថាតើសិទ្ធិនិងផលប្រយោជន៍ទាំងនេះ មានផលប៉ះពាល់ដោយរបៀបណា ពីប្រធានបទដែលសហមេធាវីនាំមុខ បានលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខនេះ[14]។ មិនចាំបាច់លើកឡើងវិញនូវទឡ្ហីករណ៍ទាំងអស់នោះឡើយ។

7. ការកត់សម្គាល់របស់មេធាវីការពារក្ដី ក៏បានលើកឡើងដោយខុសឆ្គង អំពីលក្ខខណ្ឌតម្រូវរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធទំនាក់ទំនងរវាងសារណារបស់សហមេធាវីនាំមុខ និងការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព")។ គោលជំហររបស់មេធាវីការពារក្ដី គឺហាក់បីដូចជាថា សហមេធាវីនាំមុខមិន

---

[12] ឯកសារ **F10/2** សេចក្ដីសម្រេចលើសំណើ របស់សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១៤ [ដោយគូសបញ្ជាក់បន្ថែម]។

[13] សូមមើល ឯកសារ **F60/1** ការកត់សម្គាល់របស់ មេធាវីការពារក្ដី កថាខណ្ឌ ២៤។

[14] ជាពិសេសនៅត្រង់ ឯកសារ **F54/2** ចម្លើយតបរបស់ សហមេធាវីនាំមុខ កថាខណ្ឌ ៤៣-៥៧។

អាចពិភាក្សាអំពីប្រធានបទណា ដែល ក.ស.ព បានពិភាក្សាដែរនោះទេ[15]។ នេះមិនមែនជាចេតនារបស់អង្គជំនុំជម្រះឡើយ។ ដោយសារតែ ក.ស.ព ពិភាក្សាអំពី "មូលដ្ឋាន" *ទាំងអស់* ដែលមេធាវីការពារក្តីបានលើកឡើង នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ផលវិបាកនៃគោលជំហរ ដែលមេធាវីការពារក្តីប្រកាន់យក គឺថា សហមេធាវីនាំមុខមិនត្រូវបានអនុញ្ញាតឲ្យលើកឡើងនូវសារណាណាមួយនោះឡើយ។

8. តាមពិតទៅ អង្គជំនុំជម្រះបានបង្គាប់ថា សហមេធាវីនាំមុខ ចាំបាច់ត្រូវ "ជៀសវាងភាពច្រំដែលនិងការត្រួតគ្នាជាមួយនឹងបញ្ហា ដែលបានលើកឡើងនៅក្នុងសារណារបស់សហព្រះរាជអាជ្ញា"[16]។ ដោយគោរពតាមលក្ខខណ្ឌតម្រូវនេះ សហមេធាវីនាំមុខបានពិភាក្សាតែប្រធានបទដែលលើកឡើងរួចហើយដោយ ក.ស.ព ដើម្បីលើកទឡ្ហីករណ៍ផ្សេង ឬបន្ថែមប៉ុណ្ណោះ។ និយាយម្យ៉ាងទៀត សារណាដែលបានលើកឡើង មិនមែនជាការលើកឡើងដដែលៗ ដូចសារណារបស់ ក.ស.ព ឡើយ។ នៅពេលព្រាងសារណាចម្លើយតបរបស់ខ្លួន សហមេធាវីនាំមុខសម្រេចមិនពិភាក្សាលើប្រធានបទមួយចំនួន ឬបង្រួមសារណារបស់ខ្លួនយ៉ាងច្រើន លើប្រធានបទនោះ ដោយសារតែគោលជំហររបស់សហមេធាវីនាំមុខលើប្រធានបទទាំងនោះ គឺដូចគ្នានឹងទឡ្ហីករណ៍ ដែល ក.ស.ព បានលើកឡើងរួចហើយ[17]។ សហមេធាវីនាំមុខ មិនបានដាក់សារណាលើ "មូលដ្ឋាន" ជិតពាក់កណ្តាល ដែលបានលើកឡើងក្នុងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី[18]។

9. សហមេធាវីនាំមុខយល់ឃើញច្បាស់ណាស់ថា អង្គជំនុំជម្រះបានពិចារណារួចហើយអំពីតួនាទីជាក់លាក់របស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកាលវិភាគសវនាការដែលបានស្នើឡើង។ ភាពច្បាស់លាស់នោះគឺត្រង់ថា ពេលវេលាដែលបែងចែកសម្រាប់សហមេធាវីនាំមុខ មានរយៈពេលតិចគួរ

---

[15] សូមមើលជាឧទាហរណ៍ ឯកសារ F60/1 ការកត់សម្គាល់របស់ មេធាវីការពារក្តី កថាខណ្ឌ៣៩។

[16] ឯកសារ F52/1 សេចក្តីសម្រេចលើសំណើពាក់ព័ន្ធនឹងសារណាតបរបស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ១២។

[17] ចំណុចនេះត្រូវបានលើកជាទូទៅនៅក្នុង ឯកសារ F54/2 ចម្លើយតបរបស់ សហមេធាវីនាំមុខ, កថាខណ្ឌ ៥៤ និង ៥៦-៥៧។ ចំពោះបញ្ហាជាក់លាក់ សូមមើលផងដែរ កថាខណ្ឌ ៧៧, ៨២, ៨៩, ១១២, ១២០, ១២៩, ១៦៧, ១៨២, ២៤០២៤១, ២៣៧, ២៣៨, ២៣៩, ៣១៧, ៣៣៧ (ជើងទំព័រ ៨00) ៣៧៦, ៣៨០, ៤៤៩, ៥០១, ៧៥៣ និង ៨៣៤។

[18] សូមមើល ឯកសារ F54/2.1 ចម្លើយតបរបស់ សហមេធាវីនាំមុខ ឧបសម្ព័ន្ធ កៈ ឧបសម្ព័ន្ធនៃមូលដ្ឋាន និងចម្លើយតបរបស់មេធាវីការពារក្តី។ ឧបសម្ព័ន្ធនោះបង្ហាញថា សហមេធាវីនាំមុខ មិនបានលើកសេចក្តីសន្និដ្ឋានលើ "មូលដ្ឋាន" ១២២ ក្នុងចំណោមមូលដ្ឋាន ២៥៦ ដែលមេធាវីការពារក្តីបានលើកឡើង។

សម សម្រាប់ប្រធានបទមួយចំនួន និងការពិតដែលពុំមានការបែងចែកពេលវេលា សម្រាប់ផ្នែកការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ ខៀវ សំផន។ ហេតុដូច្នេះ មិនអាចផ្តល់យុត្តិកម្មសម្រាប់ការកែសម្រួលលើមូលដ្ឋាននេះឡើយ។

## IV. ចម្លើយតបទៅនឹងសំណើកាលវិភាគ

10. ជាចុងក្រោយ សហមេធាវីនាំមុខ ឆ្លើយតបចំពោះសំណើរបស់មេធាវីការពារក្តី សម្រាប់ការបែងចែកដាក់ដោយឡែក នូវពេលវេលា៣០នាទី សម្រាប់ទឡ្ហីករណ៍ពាក់ព័ន្ធនឹងការពន្យាពេលការផ្សព្វផ្សាយជាសាធារណៈ នូវសំអាងហេតុជាលាយលក្ខណ៍អក្សរ សម្រាប់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[19]។ មេធាវីការពារក្តីមិនបានផ្តល់សំអាងហេតុថា ហេតុអ្វីទើបប្រធានបទនេះមិនអាចពិភាក្សាបាននៅក្នុងពេលវេលាដែលបានបែងចែក សម្រាប់ប្រធានបទ "ភាពយុត្តិធម៌ក្នុងកិច្ចដំណើរការនីតិវិធី" ដែលច្បាស់ណាស់ថា គ្របដណ្តប់លើប្រធានបទនេះ។

11. សហមេធាវីនាំមុខមិនជំទាស់ឡើយ ដែលអង្គជំនុំជម្រះផ្តល់ពេលវេលាដល់សហមេធាវីការពារក្តីជនជាប់ចោទ នៅក្នុងវគ្គចុងក្រោយនោះ។ ចំពោះការកែតម្រូវពេលវេលាដទៃទៀត ដែលមេធាវីការពារក្តីស្នើសុំ សហមេធាវីនាំមុខមិនមានមតិយោបល់ឡើយ ប៉ុន្តែសហមេធាវីនាំមុខស្នើសុំដោយគោរពថា ប្រសិនបើពេលវេលាដែលផ្តល់ជូនមេធាវីការពារក្តី ត្រូវបានបង្កើននោះ ពេលវេលាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះបានស្នើឡើង ក៏គួរតែបង្កើនឲ្យសមាមាត្រគ្នាផងដែរ។

## V. សំណើ

12. ហេតុដូច្នេះ សហមេធាវីនាំមុខ សូមស្នើដោយគោរពដល់អង្គជំនុំជម្រះ មេត្តា៖

**បដិសេធ** ដោយសារមិនអាចទទួលយកបាន ឬលើអង្គសេចក្តី ចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តី ពាក់ព័ន្ធសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង

**បដិសេធ** សំណើរបស់មេធាវីការពារក្តី សុំឲ្យមានវគ្គផ្សេងដាច់ដោយឡែក ពាក់ព័ន្ធនឹងការពន្យារពេលការផ្សព្វផ្សាយជាសាធារណៈ នូវសំអាងហេតុជាលាយលក្ខណ៍អក្សរ សម្រាប់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និង

[19] ឯកសារ **F60/1** ការកត់សម្គាល់របស់ មេធាវីការពារក្តី កថាខណ្ឌ ៣២-៣៣។

**អនុញ្ញាត** ផ្ដល់ជូនដល់សហមេធាវីនាំមុខ នូវពេលវេលាបន្ថែម ដែលសមាមាត្រជាមួយពេលវេលាបន្ថែមណាមួយ ដែលផ្ដល់ជូនមេធាវីការពារក្ដី។

ដោយសេចក្ដីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ | ពេជ អង្គ<br>សហមេធាវីនាំមុខជាតិ | រាជធានីភ្នំពេញ | |
| | Megan HIRST<br>សហមេធាវីនាំមុខអន្តរជាតិ | រាជធានីភ្នំពេញ | |